មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ៥

# ៥ - ឯកគ្គតាចេតសិក (One-Pointedness)

ឯកគ្គតាចេតសិក ជាធម្មជាតិស្ងប់ និងធ្វើឲ្យសម្បយុត្តធម៌ តាំងនៅក្នុងអារម្មណ៍តែមួយដូចគ្នា។

នានាលម្ពនវិក្ខេបាភាវេន ឯកំ អារម្មណំ អគ្គំ ឥមិស្សាតិ ឯកគ្គំ ចិត្តំ តស្ស ភាវោ = ឯកគ្គតា ចិត្តដែលឈ្មោះថា ឯកគ្គៈ ដោយអត្ថថា មានអារម្មណ៍តែមួយ ព្រោះមិនមានសេចក្ដីរវើរវាយ ទៅក្នុងអារម្មណ៍ផ្សេងៗ ភាវៈនៃចិត្តមានអារម្មណ៍តែមួយនោះ ឈ្មោះថា ឯកគ្គតា។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# លក្ខណាទិចតុក្កៈរបស់ឯកគ្គតា

| | |
|---|---|
| ១. អវិក្ខេបលក្ខណា | មានការមិនរវើរវាយ ជាលក្ខណៈ |
| ២. សហជាតានំ សម្បិណ្ឌនរសា | មានការប្រមូលសហជាតធម៌មកជាកិច្ច |
| ៣. ឧបសមបច្ចុប្បដ្ឋានា | មានការចូលទៅស្ងប់ ជាអាការប្រាកដ |
| ៤. សុខបទដ្ឋានា | មានសុខវេទនា ជាហេតុជិត។ |

# ៦ - ជីវិតិន្ទ្រិយចេតសិក (Psychic life)

ជីវិតិន្ទ្រិយចេតសិក ជាធម៌រក្សាសម្បយុត្តធម៌ គឺ ធ្វើឲ្យសម្បយុត្តធម៌តាំងនៅនិងប្រព្រឹត្តទៅ។ ធម៌ដែលឈ្មោះថា ឥន្ទ្រិយ ព្រោះភាពជាធំ ក្នុងការរក្សាធម៌ដែលកើតរួមគ្នា។

ជីវន្តិ តេន សម្បយុត្តធម្មាតិ ជីវិតំ តទេវ សហជាតានុបាលនេ អធិបច្ចយោគេន ឥន្ទ្រិយន្តិ = ជីវិតិន្ទ្រិយំ ឈ្មោះថា ជីវិត ព្រោះអត្ថថា ជាគ្រឿងតាំងនៅនៃសម្បយុត្តធម៌។ ជីវិតនោះឯង ជាធំក្នុងការរក្សាសហជាតធម៌ ដោយគួរដល់ សេចក្តីជាធំ ព្រោះដូច្នោះ ទើបឈ្មោះថា ជីវិតិន្ទ្រិយ។

# លក្ខណាទិចតុក្កៈរបស់ជីវិតិន្ទ្រិយ

| | |
|---|---|
| ១ - សហជាតានំ អនុបាលនលក្ខណំ | មានការតាមរក្សាសហជាតធម៌ ជាលក្ខណៈ *(ប្រៀបដូចទឹករក្សាផ្កាឈូកជាដើម)* ។ |
| ២ - តេសំ បវត្តនរសំ | មានការញ៉ាំងសម្បយុត្តធម៌ឲ្យប្រព្រឹត្តទៅ ជាកិច្ច |
| ៣ - តេសញ្ញេវ ឋបនបច្ចុប្បដ្ឋានំ | មានការតាំងនៅនៃសហជាតធម៌ ជាអាការប្រាកដ |
| ៤ - សេសខន្ធត្តយបទដ្ឋានំ | មានខន្ធ ៣ ដែលនៅសល់ ជាហេតុជិត។ |